## ២_សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្ដីសំរេចលេខ ២៩ សសរ**

**ស្ដីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល**

===

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅប្រទេសជប៉ុន ដើម្បីចូលរួមសន្និសីទអន្តរជាតិស្ដីពីអនាគតអាស៊ី ទស្សនកិច្ចនៅខេត្តអូអ៊ីតានិងចូលរួមកិច្ចប្រជុំក្រុមពិគ្រោះយោបល់ជាមួយសហគមន៍អ្នកផ្ដល់ជំនួយ ចាប់ពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០១ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និង ឯកឧត្ដម **ស ខេង** ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

www.pheakdeylaw.com